ថ្ងៃទី9 ខែធ្នូ ឆ្នាំ2009

# ក្រមសីលធមិសម្រាប់អ្នកផ្គត់ផ្គង់

## សេចក្តីផ្តើម

1. ក្នុងនាមជាស្ថាប័នផ្តល់ជំនួយចំបងក្នុងការប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ របេង និងគ្រុនចាញ់ មូលនិធិសកល (Global Fund) ដឹងពីសារៈសំខាន់នៃគណនេយ្យភាពសម្រាប់អ្នកផ្គត់ផ្គង់ ព្រមទាំងតម្លាភាព និងភាពអាចប្រមើលទុកបាន នៅក្នុងប្រតិបត្តិការរបស់ខ្លួន ។

2. ដូចដែលបានចែងនៅក្នុងឯកសារក្របខ័ណ្ឌរបស់មូលនិធិសកល គោលការណ៍ស្នូលរបស់មូលនិធិសកល គឺប្រតិបត្តិក្នុងលក្ខណៈបើកចំហ ប្រកបដោយតម្លាភាព និងគណនេយ្យភាព ។ ស្របគ្នាជាមួយនឹងគោលការណ៍ស្នូលនេះ មូលនិធិសកលនឹងធ្វើការដើម្បីឱ្យប្រាកដថាគ្រប់សកម្មភាពផ្តល់ជំនួយរបស់ខ្លួន រួមមានប្រតិបត្តិការផ្តល់ជំនួយ និងលទ្ធកម្មរួម (corporate procurement) ព្រមទាំងបុគ្គលិករបស់មូលនិធិសកល គោរពបទដ្ឋានសីលធម៌ខ្ពស់បំផុត ។

3. គោលដៅនៃក្រមសីលធម៌ ("ក្រម") នេះគឺរៀបរាប់ការតាំងចិត្តរបស់អ្នកផ្គត់ផ្គង់ ក្នុងការថែរក្សាភាពសុចរិតនៃសកម្មភាពលទ្ធកម្ម រួមនិងប្រតិបត្តិការផ្តល់ជំនួយដែលផ្តល់មូលនិធិដោយមូលនិធិសកល ស្របតាមគោលការណ៍ស្នូលរបស់មូលនិធិសកលនេះ ។

4. មូលនិធិសកលនឹងត្រួតពិនិត្យសារឡើងវិញ និងកែប្រែក្រមនេះជាទៀងទាត់ នៅពេលណាដែលចាំបាច់ ដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួលក្នុងការអនុវត្តន៍ដ៏ល្អបំផុត បទពិសោធន៍ដែលបានឆ្លងកាត់ និងមតិឆ្លើយតបពីដៃគូ ។

## វិសាលភាពនៃក្រមនេះ

5. ក្រមនេះតម្រូវឱ្យគ្រប់អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ភ្នាក់ងារ អន្តរការី អ្នកប្រឹក្សាយោបល់ និងអ្នកម៉ៅការ ("អ្នកផ្គត់ផ្គង់") ទាំងអស់ រួមទាំងគ្រប់សាខា មន្ត្រី និយោជិត អ្នកម៉ៅការបន្ត ភ្នាក់ងារ និងអន្តរការីរបស់អ្នកផ្គត់ផ្គង់ទាំងអស់ (ដែលម្នាក់ៗជា"តំណាងអ្នកផ្គត់ផ្គង់") គោរពបទដ្ឋានសីលធម៌ខ្ពស់បំផុតនៅក្នុងសកម្មភាពទាំងឡាយក្រោមជំនួយរបស់មូលនិធិសកល ទាក់ទងនឹងការផ្គត់ផ្គង់ទំនិញ និង/ឬសេវាកម្មឱ្យមូលនិធិសកល ឬអ្នកទទួលជំនួយណាមួយពីមូលនិធិសកល ដែលរួមមានអ្នកទទួលជំនួយផ្ទាល់ អ្នកទទួលជំនួយបន្ត អ្នកទទួលជំនួយដ៏ទៃទៀត យន្តការសម្របសម្រួលរបស់ប្រទេស ភ្នាក់ងារលទ្ធកម្ម និងអ្នកទិញជួរមុខ/ទីមួយ ។

6. អ្នកទទួលជំនួយផ្ទាល់ អ្នកទទួលជំនួយបន្ត អ្នកទទួលជំនួយដ៏ទៃទៀត យន្តការសម្របសម្រួលរបស់ប្រទេស ភ្នាក់ងារលទ្ធកម្ម និងអ្នកទិញជួរមុខ ត្រូវធានាថាក្រមនេះត្រូវបានផ្សព្វផ្សាយ និងអនុវត្តតាម

ដោយអ្នកផ្គត់ផ្គង់ទាំងអស់របស់ពួកគេ ។ អ្នកផ្គត់ផ្គង់នឹងធានាថា ក្រុមនេះត្រូវបានផ្សព្វផ្សាយដល់តំណាងអ្នកផ្គត់ផ្គង់របស់ពួកគេទាំងអស់ និងត្រូវចាត់វិធានការសមរម្យក្នុងការធានាឱ្យមានការអនុវត្តន៍តាម ដោយតំណាងអ្នកផ្គត់ផ្គង់ រួមទាំងការចាត់វិធានការជាបន្ទាន់ក្នុងករណីដែលមិនអនុវត្តតាម ។ ការប្រព្រឹត្តបទល្មើសលើក្រមនេះ អាចធ្វើឱ្យមូលនិធិសកលសម្រេចចិត្តដាក់ទណ្ឌកម្មអ្នកផ្គត់ផ្គង់ និង/ឬតំណាងអ្នកផ្គត់ផ្គង់ដែលពាក់ព័ន្ធ ផ្អាកការផ្តល់ថវិកាឱ្យអ្នកទទួលជំនួយ ឬលុបចោលការផ្តល់ជំនួយ ។

## ការអនុវត្តន៍ដែលមានតម្លាភាពនិងយុត្តិធម៌

7. មូលនិធិសកលមិនអត់ឱនឱ្យអំពើពុករលួយ ក្លែងបន្លំ ឃុបឃិត ប្រឆាំងនឹងការប្រកួតប្រជែង ឬបង្ខិតបង្ខំ ក្នុងរូបភាពណាមួយក៏ដោយ ទាក់ទងនឹងធនធានមូលនិធិ រួមទាំងថវិកាជំនួយ ។ មូលនិធិសកលនឹងចាត់វិធានការម៉ឺងម៉ាត់ជាបន្ទាន់នៅគ្រប់កាលៈទេសៈទាំងអស់ដែលមូលនិធិកំណត់ថាមានភស្តុតាងសំខាន់ និងជឿជាក់បានអំពីអំពើពុករលួយ ក្លែងបន្លំ ឃុបឃិត ប្រឆាំងនឹងការប្រកួតប្រជែង ឬបង្ខិតបង្ខំ ដូចដែលមានអត្ថន័យដូចខាងក្រោម ។

8. អ្នកផ្គត់ផ្គង់ និងតំណាងអ្នកផ្គត់ផ្គង់ត្រូវបានសង្ឃឹមថានឹងចូលរួមក្នុងដំណើរការលទ្ធកម្ម ក្នុងលក្ខណៈមួយដែលមានតម្លាភាព យុត្តិធម៌ គណនេយ្យភាព និងស្មោះត្រង់ ដែលរួមទាំងការអនុវត្តន៍តាមច្បាប់ និងបទប្បញ្ញត្តិនានាដែលត្រូវអនុវត្ត ទាក់ទងនឹងការប្រកួតប្រជែងដោយយុត្តិធម៌ ក៏ដូចជាបទដ្ឋាននៃ ការអនុវត្តន៍ល្អក្នុងការធ្វើលទ្ធកម្មដែលគេទទួលស្គាល់ ។

9. អ្នកផ្គត់ផ្គង់ និងតំណាងអ្នកផ្គត់ផ្គង់ត្រូវបានសង្ឃឹមថានឹងឆ្លើយតបនឹងសំណូមពរ ក្នុងលក្ខណៈស្មោះត្រង់ យុត្តិធម៌ និងគ្រប់ជ្រុងជ្រោយ ដោយឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវពីសមត្ថភាពរបស់ពួកគេក្នុងការបំពេញលក្ខខ័ណ្ឌតម្រូវទាំងឡាយ ដែលបានកំណត់នៅក្នុងឯកសារកិច្ចសន្យា ឬឯកសារដេញថ្លៃ ។ ពួកគេត្រូវបានសង្ឃឹមថានឹងធ្វើតាមវិធានទាំងអស់ ដែលបានបង្កើតឡើងសម្រាប់ដំណើរការលទ្ធកម្មនីមួយៗ ហើយអាចដាក់ការដេញថ្លៃ និងចូលរួមក្នុងកិច្ចសន្យាបាន លុះត្រាតែពួកគេមានសមត្ថភាពហើយនឹងបំពេញកាតព្វកិច្ចទាំងអស់ក្នុងកិច្ចសន្យា ។

10. អ្នកផ្គត់ផ្គង់ និងតំណាងអ្នកផ្គង់ផ្គង់នឹងមិនត្រូវពាក់ព័ន្ធដោយផ្ទាល់ឬដោយប្រយោល (រួមទាំងតាម-រយៈភ្នាក់ងារ ឬអន្តរការីដ៏ទៃទៀត) ទៅនឹងអំពើពុករលួយ ក្លែងបន្លំ ឃុបឃិត ការប្រឆាំងនឹងការប្រកួតប្រជែង ឬបង្ខិតបង្ខំ នៅក្នុងការដេញថ្លៃ ឬដំណើរការសកម្មភាពឬកិច្ចសន្យាក្រោមជំនួយរបស់មូលនិធិសកលនោះទេ ។ សម្រាប់គោលបំណងទាំងនេះ ៖

> "អំពើពុករលួយ" មានន័យថាការផ្តល់ឱ្យ ការសន្យា ការឱ្យ ការទទួល ឬទទូចសុំ ដោយផ្ទាល់ឬដោយប្រយោលនូវអ្វីមួយដែលមានតម្លៃ ឬផលប្រយោជន៍ណាមួយ ក្នុងគោលបំណងជះឥទ្ធិ-ពលអសុក្រឹតដល់សកម្មភាពនានារបស់បុគ្គលឬអង្គភាពផ្សេងទៀត ។

"អំពើក្លែងបន្លំ" មានន័យថាសកម្មភាព ឬការលុបបំបាត់ណាមួយ ដែលរួមមានការថ្លែងបោក-ប្រាស់ដោយផ្ទាល់ឬដោយប្រយោល ដែលនាំឱ្យយល់ខុសដោយចេតនាឬដោយធ្វេសប្រហែស ឬប៉ុនប៉ងធ្វើឱ្យបុគ្គល ឬអង្គភាពណាមួយយល់ខុស ដើម្បីទទួលយកផលប្រយោជន៍ជាថវិកា ឬផលប្រយោជន៍ផ្សេងៗ ឬក្នុងគោលបំណងគេចវេសកាតព្វកិច្ចណាមួយ ។

"អំពើបង្ខិតបង្ខំ" មានន័យថា

សកម្មភាព ឬសេចក្តីប៉ុនប៉ងក្នុងការជះឥទ្ធិពលដោយមិនត្រឹមត្រូវដល់ការសម្រេចចិត្ត ឬសកម្ម-ភាពរបស់បុគ្គល ឬអង្គភាពមួយ តាមរយៈការធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ឬធ្វើបាបបុគ្គលនោះ ឬអង្គភាពនោះ ឬគម្រាមថានឹងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ឬធ្វើបាបបុគ្គលនោះ ឬអង្គភាពនោះ ដោយផ្ទាល់ឬដោយប្រយោល ។

"អំពើឃុបឃិត" មានន័យថាការរៀបចំរវាងបុគ្គល ឬអង្គភាពពីរ ឬច្រើន ដែលគេរៀបចំដើម្បីសម្រេចគោលបំណងមិនត្រឹមត្រូវណាមួយ រួមមានការជះឥទ្ធិពលដោយមិនត្រឹមត្រូវដល់សកម្មភាពរបស់បុគ្គលឬអង្គភាមួយផ្សេងទៀត ។

"អំពើប្រឆាំងនឹងការប្រកួតប្រជែង" មានន័យថាការព្រមព្រៀង ការសម្រេចចិត្ត ឬអំពើណាមួយ ដែលមានកម្មវត្ថុ ឬជះឥទ្ធិពលដល់ការរឹតបន្តឹង ឬការប្រែប្រួលខុសពីភាពដើមដល់ការប្រកួតប្រជែងក្នុងទីផ្សារណាមួយ ។

11. អ្នកផ្គត់ផ្គង់ និងតំណាងអ្នកផ្គត់ផ្គង់ នឹងមិនសំណូមពរ ស្នើឱ្យ ផ្តល់ឱ្យ ឬទទួល ឬសន្យា ឬបង្ហាញការស្នើឱ្យ ផ្តល់ឱ្យ ឬទទួលថ្លៃកម្រៃទឹកតែ សំណង អំណោយ កម្រៃជើងសារ ឬការបង់ថវិកាផ្សេងទៀតនោះទេ លើកលែងតែអស់ទាំងនេះបានលាតត្រដាងទាំងមូលឱ្យមូលនិធិសកល ឬអ្នកទទួលជំនួយដឹង ទាក់ទងនឹងដំណើរការលទ្ធកម្ម ឬក្នុងប្រតិបត្តិការកិច្ចសន្យា ។

12. ក្នុងកាលៈទេសៈណាក៏ដោយ ព័ត៌មាន ទិន្នន័យ ចំណេះដឹង និងឯកសារដែលទទួលបានពីការចូលរួមក្នុងមូលនិធិសកល ឬដំណើរការលទ្ធកម្មនៃការទទួលជំនួយ ឬពីការអនុវត្តន៍កិច្ចសន្យាក្រោមជំនួយមូលនិធិសកល មិនត្រូវផ្សព្វផ្សាយទៅកាន់ភាគីទីបីណាមួយឱ្យដឹងក្នុងគោលបំណងធ្វើឱ្យអ្នកផ្គត់ផ្គង់ដែលមានស្រាប់ ឬអ្នកផ្គត់ផ្គង់ដែលមានសក្តានុភាព មានប្រៀប ឬទទួលផលប្រយោជន៍ទាក់ទងនឹងសំណើ ឬដំណើរការលទ្ធកម្មណាផ្សេងទៀតរបស់មូលនិធិសកល ឬអ្នកទទួលជំនួយដែលត្រូវការ មុនពេលមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីមូលនិធិសកលនោះទេ ។

**ការអនុវត្តន៍តាមច្បាប់**

13. អ្នកផ្គត់ផ្គង់ និងតំណាងអ្នកផ្គត់ផ្គង់ នឹងអនុវត្តតាមច្បាប់ និងបទបញ្ញាដែលត្រូវអនុវត្តទាំងអស់នៅក្នុងប្រទេសដែលពួកគេធ្វើពាណិជ្ជកម្ម ក៏ដូចជាវិន័យដែលបានផ្សព្វផ្សាយជាសាធារណៈ បទបញ្ញា និងគោលនយោបាយរបស់មូលនិធិសកលដែលត្រូវអនុវត្តក្នុងកិច្ចការងាររបស់ពួកគេ ។

14. អ្នកផ្គត់ផ្គង់ និងតំណាងអ្នកផ្គត់ផ្គង់នឹងធានាថា ធនធានរបស់មូលនិធិសកលដែលពួកគេបានទទួល មិនត្រូវបានប្រើប្រាស់ក្នុងការឧបត្ថម្ភ ផ្តល់ជំនួយ ឬលើកកម្ពស់អំពើហឹង្សា ឧបត្ថម្ភភាវរជន ឬសកម្មភាពទាក់ទងនឹងភាវរកម្ម ឬឧបត្ថម្ភអង្គការដែលត្រូវបានគេដឹងថាជាស្ថាប័នគាំទ្រភាវរកម្ម នោះទេ ។

15. អ្នកផ្គត់ផ្គង់ និងតំណាងអ្នកផ្គត់ផ្គង់ នឹងមិនពាក់ព័ន្ធជាមួយនឹងសកម្មភាពលាងលុយនោះទេ ។ នេះរួមមាន សកម្មភាពប្រភេទណាក៏ដោយដែលលាក់បាំង ឬមានចេតនាលាក់បាំងការពិតថាជំនួយដែលគេបានទទួលខុសច្បាប់ ឬជាប់ពាក់ព័ន្ធនឹងនិតិវិធីព្រហ្មទណ្ឌ ដូចជាតាមរយៈការក្លែងបន្លំ ឬសូកប៉ាន់ ឬអំពើខុសច្បាស់ផ្សេងទៀត ។

## លទ្ធភាពទទួលបាន និងកិច្ចសហប្រតិបត្តិការ

16. អ្នកផ្គត់ផ្គង់ និងតំណាងអ្នកផ្គត់ផ្គង់ត្រូវថែរក្សារបាយការណ៍ពេញលេញ និងត្រឹមត្រូវនៅក្នុងសៀវភៅគណនេយ្យលំហូរចេញចូលអាជីវកម្ម និងហិរញ្ញវត្ថុទាំងអស់ ដ៏សមរម្យមួយ ក្រោមកិច្ចសន្យាផ្តល់ជំនួយដោយមូលនិធិសកល រយៈពេលយ៉ាងតិចបំផុតប្រាំឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការបង់ថ្លៃចុងក្រោយបំផុតនៅក្នុងកិច្ចសន្យាផ្តល់ជំនួយដោយមូលនិធិសកល ។

17. នៅក្នុងគំនិតរបស់មូលនិធិសកល អ្នកផ្គត់ផ្គង់ និងតំណាងអ្នកផ្គត់ផ្គង់ត្រូវសហការជាមួយនឹងមូលនិធិសកល និងអនុវត្តតាមសេចក្តីស្នើសុំសមហេតុផលរបស់ការិយាល័យត្រួតពិនិត្យទូទៅរបស់មូលនិធិ (OIG) និងភ្នាក់ងារដ៏ទៃទៀត ឬតំណាងរបស់មូលនិធិសកល ដើម្បីធ្វើឱ្យមានលទ្ធភាពចូលទៅកាន់បុគ្គលិកពាក់ព័ន្ធ និងដើម្បីត្រួតពិនិត្យមើលគណនេយ្យ និងរបាយការណ៍ពាក់ព័ន្ធ ព្រមទាំងឯកសារដ៏ទៃទៀតទាក់ទងនឹងការដេញថ្លៃ និងដំណើរការកិច្ចសន្យាផ្តល់ជំនួយដោយមូលនិធិសកល។

18. អ្នកផ្គត់ផ្គង់ និងតំណាងអ្នកផ្គត់ផ្គង់នឹងផ្តល់ជំនួយដែលមូលនិធិសកលស្នើសុំនៅពេលណាក៏បាន ដើម្បីជម្រុញឱ្យមូលនិធិសកលអនុវត្តតាមលក្ខខ័ណ្ឌបទបញ្ញាស្របច្បាប់ ឬកំណត់ដោយច្បាប់ ដែលមូលនិធិត្រូវអនុវត្ត ។

19. មូលនិធិសកលសង្ឃឹមថាអ្នកទទួលជំនួយរបស់មូលនិធិ នឹងចាត់វិធានការសមរម្យតាមពេលវេលាក្នុងស្ថានភាពទាំងឡាយណាដែលអ្នកទទួលជំនួយដឹងថា តំណាងណាមួយរបស់គេ ឬអ្នកទទួលផលពីកិច្ចសន្យាផ្តល់ជំនួយដោយមូលនិធិសកលបានពាក់ព័ន្ធ ឬសង្ស័យថាបានពាក់ព័ន្ធនឹងអំពើពុករលួយ ក្លែងបន្លំ ឃុបឃិត ប្រឆាំងនឹងការប្រកួតប្រជែង ឬបង្ខិតបង្ខំទាក់ទងនឹងលទ្ធកម្ម ឬដំណើរការ

កិច្ចសន្យានោះ ។ មូលនិធិសកលនឹងផ្តន្ទាទោសដែលមូលនិធិគិតថាចាំបាច់ ប្រសិនបើមូលនិធិពិចារណានៅពេលណាមួយថា អ្នកទទួលជំនួយមិនបានចាត់វិធានការត្រឹមត្រូវតាមពេលវេលាដែលគួរឱ្យមូលនិធិសកល ពេញចិត្តក្នុងស្ថានភាពបែបនេះ ។

## ការប្រកាសជាសាធារណៈ និងការផ្សព្វផ្សាយ

20. មុនពេលមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីមូលនិធិសកល អ្នកផ្គត់ផ្គង់ និងតំណាងអ្នកផ្គត់ផ្គង់ នឹងមិន (i)ប្រើប្រាស់ឈ្មោះឬស្លាកសញ្ញារបស់មូលនិធិសកល ក្នុងការប្រកាសជាសាធារណៈ និងក្នុងការផ្សព្វផ្សាយនោះទេ (ii)ប្រើប្រាស់ទំនាក់ទំនងពាណិជ្ជកម្មដោយផ្ទាល់ ឬដោយប្រយោលរបស់ពួកគេជាមួយនឹងមូលនិធិសកល ក្នុងការកំណត់ន័យបដិលេខចេញពីមូលនិធិសកលទាក់ទងនឹងទំនិញឬសេវាកម្ម របស់ពួកគេនោះទេ និង(iii)បញ្ចេញទស្សនៈ ឬធ្វើសេចក្តីថ្លែងការណ៍តំណាងឱ្យមូលនិធិសកលនោះទេ ។

## ការលាតត្រដាងទាំងមូលដោយចំហ និងទំនាស់ផលប្រយោជន៍

21. មុនពេលចូលរួមធ្វើកិច្ចសន្យា ឬនៅពេលណាមួយក្នុងកំឡុងពេលដំណើរការកិច្ចសន្យា អ្នកផ្គត់ផ្គង់នឹងប្រាប់មូលនិធិសកលឱ្យដឹងថាតើពួកគេ ឬតំណាងអ្នកផ្គត់ផ្គង់ជាអ្នកទទួលខុសត្រូវនូវការផ្តន្ទាទោស ឬបញ្ឈប់ជាបណ្តោះអាសន្នពីអង្គការឬស្ថាប័នផ្តល់ជំនួយអន្តរជាតិចំបងណាមួយ ដូចជាសហប្រជាជាតិ ឬក្រុមធនាគារពិភពលោក ។

22. អ្នកផ្គត់ផ្គង់នឹងប្រាប់មូលនិធិសកល ឬអ្នកទទួលជំនួយឱ្យដឹងពីទំនាស់ផលប្រយោជន៍នាពេលបច្ចុប្បន្ន ឬទំនាស់ដែលបានសង្កេតឃើញ ឬទំនាស់ដែលអាចកើតឡើង ទាក់ទងនឹងអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ណាមួយ (ទំនាស់ផលប្រយោជន៍) ។ មូលនិធិសកលចាត់ទុកថាទំនាស់ផលប្រយោជន៍ គឺជាស្ថានភាពមួយដែលភាគីម្ខាងទទួលផលប្រយោជន៍ដែលអាចប៉ះពាល់យ៉ាងអសុក្រឹតទៅលើការបំពេញតួនាទី ឬកាតព្វកិច្ចស្របច្បាប់របស់ភាគីនោះ កាតព្វកិច្ចក្នុងកិច្ចសន្យា ឬការអនុវត្តន៍តាមច្បាប់ និងបទបញ្ជាដែលត្រូវអនុវត្ត ព្រមទាំងផលប្រយោជន៍ដែលក្នុងនោះ ទំនាស់ផលប្រយោជន៍អាចជួយ ឬបង្កើតសកម្មដែលត្រូវបានហាមឃាត់នៅក្នុងក្រមសីលធម៌នេះ ។ ដើម្បីធានាថាអ្នកផ្គត់ផ្គង់ក្រោមកិច្ចសន្យាផ្តល់ជំនួយដោយមូលនិធិសកល ធ្វើការកត់សម្គាល់ពីបទដ្ឋានសីលធម៌ខ្ពង់ខ្ពស់ មូលនិធិសកលនឹងចាត់វិធានការសមរម្យដើម្បីដោះស្រាយទំនាស់ផលប្រយោជន៍នេះ ឬអាចបដិសេធសំណើសុំជំនួយ ឬការផ្តល់ជំនួយ ប្រសិនបើមូលនិធិសម្រេចថាទំនាស់ផលប្រយោជន៍បាន ធ្វើឱ្យខូច ឬប្រថុយនឹងការធ្វើឱ្យខូចភាពសុច្ចរិតរបស់ដំណើរការលទ្ធកម្មណាមួយ ។

23. អ្នកផ្គត់ផ្គង់នឹងមិនប្រើប្រាស់ ឬចង់ប្រើប្រាស់ ឥទ្ធិពលមិនត្រឹមត្រូវក្នុងដំណើរការសម្រេចចិត្តរបស់មូលនិធិសកល និងមិនពាក់ព័ន្ធនឹងអំពើដែលល្មើស ឬជម្រុញឱ្យមានបទល្មើសលើគោលនយោបាយរបស់មូលនិធិសកលស្តីពីសីលធម៌ និងទំនាស់ផលប្រយោជន៍ ។ (សូមមើលឧបសម្ព័ន្ធ A)

24. អ្នកផ្គត់ផ្គង់ត្រូវផ្តល់ដំណឹងជូនមូលនិធិសកលយ៉ាងឆាប់បំផុត នៅពេលពួកគេដឹងពីបញ្ហាប៉ះពាល់ភាពសុចរិតទាក់ទង ឬប៉ះពាល់ដល់ធនធានមូលនិធិសកល និងការផ្តល់ជំនួយ មិនថាបញ្ហានោះទាក់ទងនឹងអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់នោះឡើយ ។ សម្រាប់ព័ត៌មានបន្ថែម សូមអានគេហទំព័រ http://www.theglobalfund.org/en/oig/

## កតិកាសញ្ញាជាសាកលរបស់អង្គការសហប្រជាជាតិចំពោះភាពជាក្រុមហ៊ុនអាជីវកម្មដែលមានភាពទទួលខុសត្រូវ

25. កតិកាសញ្ញាជាសកលរបស់អង្គការសហប្រជាជាតិ គឺជាបណ្តាញភាពជាក្រុមហ៊ុនអាជីវកម្មអន្តរជាតិស្ម័គ្រចិត្តមួយ ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងគាំទ្រការចូលរួមពីវិស័យឯកជន និងស្ថាប័នសង្គមផ្សេងទៀត ដើម្បីជម្រុញភាពជាក្រុមហ៊ុនអាជីវកម្មដែលមានទំនួលខុសត្រូវ និងគោលនយោបាយខាងសង្គម និងខាងបរិស្ថាននៅទូទាំងពិភពលោករីកចម្រើន ឆ្ពោះទៅរកការដោះស្រាយបញ្ហានានារបស់សកលភាវូបនីយកម្ម (សូមអាន www.unglobalcompact.org) ។ មូលនិធិសកល លើកទឹកចិត្តជាខ្លាំងឱ្យអ្នកផ្គត់ផ្គង់ទាំងអស់ចូលរួមយ៉ាងសកម្មជាមួយក្នុងកតិកាសញ្ញាជាសកលនេះ ។

26. យោងតាមគោលការណ៍ទាំងដប់ ដែលបានចែងដោយកតិកាសញ្ញាជាសកលរបស់អង្គការសហប្រជាជាតិ អ្នកផ្គត់ផ្គង់ដែលបានចូលរួមនឹងត្រូវៈ

a. គាំទ្រ និងគោរពការការពារសិទ្ធមនុស្សដែលបានប្រកាសជាអន្តរជាតិ

b. ធានាថាពួកគេមិនពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធមនុស្ស

c. គោរពសេរីភាពសមាគម និងការទទួលស្គាល់ពីសិទ្ធចុះថ្លៃជាប្រយោជន៍រួមជាក់ស្តែង ។

d. គាំទ្រការលុបបំបាត់ពលកម្មដែលជៀសមិនរួច និងពលកម្មដែលធ្វើដោយបង្ខំ ក្នុងរូបភាពបែបណាក៏ដោយ ។

e. គាំទ្រការលុបបំបាត់ពលកម្មកុមារដែលមានប្រសិទ្ធភាព ។

f. គាំទ្រការលុបបំបាត់ភាពរើសអើងក្នុងការងារនិងជីវវិជ្ជា ។

h. គាំទ្រវិធីសាស្ត្រត្រៀមបម្រុងសម្រាប់បញ្ហាបរិស្ថាន ។

i. ចាត់វិធានការលើកកម្ពស់ទំនួលខុសត្រូវចំពោះបរិស្ថានឱ្យកាន់តែខ្លាំងជាងមុន ។

j. ជម្រុញឱ្យមានការរីកចម្រើន និងការផ្សព្វផ្សាយអំពីបច្ចេកវិទ្យាដែលជួយថែរក្សាបរិស្ថាន និង

k. ប្រឆាំងនឹងអំពើពុករលួយក្នុងរូបភាពណាក៏ដោយ រួមទាំងការគំរាមកំហែង និងសូកប៉ាន់ ។

## គោលនយោបាយស្តីពីសីលធម៌និងទំនាស់ផលប្រយោជន៍ សម្រាប់ស្ថាប័នមូលនិធិសកល

### 1. គោលការណ៍ទូទៅ

1.1 មូលនិធិសកលប្រឆាំងនឹងជម្ងឺអេដស៍ របេង និងគ្រុនចាញ់ (មូលនិធិ) ត្រូវបានបង្កើតឡើងដើម្បីទាក់ទាញ គ្រប់គ្រង និងផ្តល់ធនធានបន្ថែមតាមរយៈភាពជាដៃគូថ្មីរវាងសាធារណៈ និងឯកជនដើម្បីជួយទ្រទ្រង់យ៉ាងសំខាន់ក្នុងការកាត់បន្ថយការឆ្លងជម្ងឺ និងស្លាប់បណ្តាលមកពីមេរោគហ៊ីវ ឬជម្ងឺអេដស៍ របេង និងគ្រុនចាញ់នៅក្នុងប្រទេសដែលត្រូវការ ។ ដើម្បីសម្រេចគោលដៅទាំងនេះ មូលនិធិមើលឃើញតម្រូវការទាក់ទងម្ចាស់ភាគហ៊ុនដែលមានចំណាប់អារម្មណ៍ជាច្រើន រួមទាំងរដ្ឋទទួលជំនួយ និងផ្តល់ជំនួយ សហគ្រាសរកប្រាក់ចំណេញ និងមិនរកប្រាក់ចំណេញ ព្រមទាំងសហគមន៍អន្តររដ្ឋាភិបាល និងសហគមន៍អន្តរជាតិ ។

1.2 ដោយសារតែមានចំណាប់អារម្មណ៍ និងភាពយល់ឃើញចម្រុះរបស់ម្ចាស់ភាគហ៊ុនទាំងនេះ វាគឺជាការសំខាន់មួយដែលមូលនិធិសកលដំណើរការក្នុងលក្ខណៈបើកចំហ តម្លាភាព សហការ សីលធម៌ និង ស្មើភាព ។ ដូចដែលចែងក្នុងមាត្រាទី 7.4 នៃច្បាប់មូលនិធិ គោលនយោបាយនេះផ្តល់ការណែនាំក្នុងការសម្គាល់ និងលើកបង្ហាញពីទំនាស់ផលប្រយោជន៍នាពេលបច្ចុប្បន្ន ឬផលប្រយោជន៍ដែលអាចកើតឡើង ។ វាអាស្រ័យទៅតាមនិយមន័យជាក់ស្តែងរបស់ក្តីបារម្ភ ដែលអាចកើតឡើង កាតព្វកិច្ចក្នុងការ លាតត្រដាង និងនីតិវិធីដែលបានរៀបរាប់ (រួមមានការបង្កើតគណៈកម្មាធិការត្រួតពិនិត្យសីលធម៌ និងការតែងតាំងមន្ត្រីត្រួតពិនិត្យសីលធម៌) ដើម្បីដោះស្រាយទំនាស់ទាំងនេះ ពេលកើតមានឡើង ។

1.3 គោលដៅរបស់គោលនយោបាយនេះ គឺធានាឱ្យមានភាពយុត្តិធម៌ និងបទដ្ឋានក្រមសីលធម៌ខ្ពស់ក្នុងការសម្រេចចិត្តរបស់មូលនិធិ ដើម្បីការពារកិត្តិយស និងភាពសុច្ចរិតរបស់មូលនិធិ ព្រមទាំងផល-ប្រយោជន៍របស់មូលនិធិ និងធានាឱ្យមានទំនុកចិត្ត និងភាពជឿជាក់ពីសាធារណជនទូទៅ ក្នុងការសម្រេចចិត្ត និងសកម្មភាពផ្តល់ជំនួយរបស់មូលនិធិ ។ នៅពេលណាដែលលក្ខខ័ណ្ឌគោលនយោបាយនេះមិនស្របគ្នាជាមួយនឹងច្បាប់ ឬបទបញ្ញាដែលត្រូវអនុវត្តចំពោះបុគ្គលលាក់កំបាំងនោះ លក្ខខ័ណ្ឌទាំងឡាយនោះ មិនគួរយកមកអនុវត្តនោះទេ ។ ប៉ុន្តែបើអាចទៅរួច គោលនយោបាយនេះនឹងត្រូវបានសម្រាយឱ្យស្របគ្នាជាមួយនឹងច្បាប់ ឬបទបញ្ញាដែលត្រូវយកមកអនុវត្ត ។

1.4 មូលនិធិទទួលស្គាល់ថា លក្ខណៈតំណាងរបស់ក្រុមប្រឹក្សាភិបាលរបស់មូលនិធិ និងអង្គភាពក្រោមឱវាទ នាំឱ្យកើតមានទំនាស់មកជាមួយនៅពេលក្រុមប្រឹក្សា ឬអង្គភាពអភិបាលផ្សេងទៀតរបស់មូលនិធិ ត្រូវពិចារណាលើបញ្ហាដែលមានលទ្ធផលផ្ទាល់ លើផលប្រយោជន៍រដ្ឋាភិបាល សាជីវកម្ម ឬអង្គការ ដែលកាន់តំណែងគ្រប់គ្រងនៅក្នុងមូលនិធិ ។ មូលនិធិមើលឃើញថា ទំនាស់

ផលប្រយោជន៍ស្ថាប័នទាំងនេះ អាចនឹងដោះស្រាយដោយភាពសុច្ចរិតខ្ពស់បំផុត ដើម្បីការពារប្រឆាំងនឹងការយល់ឃើញណាមួយដែលគិតថា ការចូលរួមរបស់រដ្ឋាភិបាល សាជីវកម្ម ឬអង្គការក្នុងតួនាទីណាក៏ដោយក្នុងមូលនិធិព្រមផ្តល់ផលប្រយោជន៍មិនត្រឹមត្រូវឱ្យអង្គភាពទាំងនោះ នៅក្នុងការសម្រេចចិត្តរបស់មូលនិធិ ។

## 2. និយមន័យ

(a) *បុគ្គលលាក់បំបាំង* សំដៅទៅលើសមាជិកក្រុមប្រឹក្សាមូលនិធិ (សមាជិកក្រុមប្រឹក្សា) អ្នកជំនួសសមាជិកគណៈកម្មាធិការណាមួយ កម្លាំងពលករ ក្រុមត្រួតពិនិត្យបច្ចេកទេសសារឡើងវិញ ឬអង្គភាពក្រោមឱវាទផ្សេងទៀតរបស់មូលនិធិ និងនិយោជិកលេខាធិការដ្ឋានដែលមានវិជ្ជាជីវៈ ។ [1]

*យល់ព្រមនៅថ្ងៃទី10 និងទី11 ខែតុលា ឆ្នាំ ដូចដែលបានកែតម្រូវក្នុងកិច្ចប្រជុំក្រុមប្រឹក្សាលើកទីដប់ប្រាំបី របស់មូលនិធិសកលប្រឆាំងនឹងជម្ងឺអេដស៍ របេង និងគ្រុនចាញ់ (GF/B18/8)

(b) *សហការី* សំដៅទៅលើ (i)ស្វាមី ភរិយា កូនតូច ឬដៃគូក្នុងគ្រួសាររបស់បុគ្គលលាក់បំបាំង ។

(c) ស្ថាប័នជាសហការី សំដៅទៅលើ (i)អង្គការ សាជីវកម្ម ឬរដ្ឋាភិបាលណាដែលបុគ្គលលាក់បំបាំងកំពុងបម្រើការងារជាមន្ត្រី ប្រធាន អភិបាល ដៃគូ ឬនិយោជិតដែលទទួល ឬអាចទទួលជំនួយពីមូលនិធិ ឬដែលមូលនិធិមានកិច្ចព្រមព្រៀង កិច្ចសន្យា ជំនួយ ឬទំនាក់ទំនងជាមួយ ឬ(ii)បុគ្គល អង្គការ សាជីវកម្ម រដ្ឋាភិបាល ឬស្ថាប័នស្រដៀងគ្នាណាដែលបុគ្គលលាក់បំបាំងកំពុងចរចារជាមួយ ឬមានការរៀបចំផ្តល់ការងារនាពេលខាងមុខ ។

(d) ផ្ទាល់ខ្លួន និងធំដុំ ។ ការចូលរួមដោយខ្លួនឯង មានន័យថាការចូលរួមដោយផ្ទាល់ ឬបំណងចង់ជះឥទ្ធិពលដល់លទ្ធផលនៃដំណើរការសម្រេចចិត្ត ដែលរួមមានដូចជាការពិចារណាលើបញ្ហានៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ឬការគ្រប់គ្រងអ្នកក្រោមឱវាទដោយផ្ទាល់ និងយ៉ាងសកម្មចំពោះបញ្ហានេះ ។ ការចូលរួមធំដុំ មានន័យថាការចូលរួមរបស់បុគ្គលលាក់បំបាំងមានសារៈសំខាន់ចំពោះបញ្ហានះ ។

(e) អំណោយ សំដៅទៅលើកម្រៃទឹកតែ អនុគ្រោះ ការបញ្ចុះតម្លៃ ការកំសាន្ត ការទទួលឱ្យសំណាក់អាស្រ័យដោយឥតគិតថ្លៃ បំណុល ការពន្យាពេល កិត្តិយស និងវត្ថុផ្សេងទៀតដែលមានតម្លៃ ។ ទាំងនេះរួមមានសេវាកម្ម ក៏ដូចជាអំណោយជាវគ្គបណ្តុះបណ្តាល មធ្យោបាយធ្វើដំណើរ ការធ្វើដំណើរក្នុងតំបន់ ថ្លៃសំណាក់និងអាហារ មិនថាជាការផ្តល់ជូនជារូបភាពនៃការទិញសំបុត្រ ការបង់ថ្លៃជាមុន ឬការផ្តល់ប្រាក់សងវិញបន្ទាប់ពីចំណាយ ។

(f) គណៈកម្មាធិការត្រួតពិនិត្យសីលធម៌ សំដៅទៅលើគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលមានសមាជិកក្រុមប្រឹក្សាប្រាំមួយនាក់ បង្កើតឡើងក្នុងគោលបំណងជួយអនុវត្តគោលនយោបាយស្តីពីសីលធម៌

និងទំនាស់ផលប្រយោជន៍ និងដើម្បីជៀសវាងស្ថានភាពណាដែលអាចប៉ះពាល់ដល់កិត្តិយស និងភាពសុច្ចរិតរបស់មូលនិធិ ។

(ឫ) មន្ត្រីត្រួតពិនិត្យសីលធម៌ សំដៅទៅលើនិយោជិតលេខាធិការដ្ឋាន ដែលតែងតាំងដោយប្រធានប្រតិបត្តិនៃលេខាធិការដ្ឋានមូលនិធិ ដើម្បីជួយគណៈកម្មាធិការត្រួតពិនិត្យសីលធម៌ក្នុងកិច្ចការងាររបស់គណៈកម្មាធិការ ។

**3. ទំនាស់ផលប្រយោជន៍**

3.1 ទំនាស់ផលប្រយោជន៍កើតឡើង នៅពេលដែលបុគ្គលលាក់បំបាំងចូលរួមដោយខ្លួនឯង និងធំដុំនៅក្នុងបញ្ហាជាក់លាក់ណាមួយរបស់មូលនិធិសកល ដែលបុគ្គលនោះ ឬសហការី ឬស្ថាប័នជាសហការីទទួលផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ដែលគាត់ដឹង ប្រសិនបើបញ្ហាជាក់លាក់នោះអាចជះឥទ្ធិពលផ្ទាល់ ឬទាយទុកជាមុនលើផលប្រយោជន៍នោះ។ [2] ជាទូទៅ និងគ្មានដែនកំណត់ ទំនាស់អាចត្រូវគេឃើញថាមានកើតឡើងនៅក្នុងស្ថានភាពដូចខាងក្រោម៖

• ស្ថានភាពដែលផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុរបស់បុគ្គលលាក់បំបាំង ឬផលប្រយោជន៍របស់សហការី ឬស្ថាប័នជាសហការី អាចប៉ះពាល់ដល់ការបំពេញតួនាទី និងទំនួលខុសត្រូវរបស់សហការី ឬស្ថាប័នទាក់ទងនឹងមូលនិធិ ឬនាំឱ្យកើតមានការយល់ឃើញសមហេតុផលមួយ ដែលនាំឱ្យមានទំនាស់បែបនេះ។
• ស្ថានភាពដែលសកម្មភាពរបស់បុគ្គលលាក់បំបាំងធ្វើឱ្យខូចខាត ឬអន្តរាយដល់ទំនុកចិត្តដែលសាធារណជនមានឱ្យមូលនិធិ និង
• ស្ថានភាពដែលសកម្មភាពរបស់បុគ្គលលាក់បំបាំងបង្កើតការយល់ឃើញថា បុគ្គលលាក់បំបាំងកំពុងប្រើប្រាស់តួនាទីរបស់ខ្លួននៅក្នុងមូលនិធិ រកផលប្រយោជន៍បុគ្គល ឬរកផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុផ្ទាល់ឱ្យស្ថាប័នជាសហការី ។

ឧទាហរណ៍ជាក់លាក់នៃទំនាស់បែបនេះរួមមាន៖

• *សមាជិកក្រុមប្រឹក្សាគាំទ្រការយល់ស្របផ្តល់ថវិកាជំនួយដែលរដ្ឋាភិបាល អង្គភាព ឬអង្គការរបស់ខ្លួននឹងបម្រើការងារជាអ្នកទទួលផ្ទាល់ ភ្នាក់ងារអនុវត្ត ភ្នាក់ងារជំនួយក្នុងតំបន់ ឬដើរតួជាអ្នកអនុវត្តគម្រោងដោយផ្ទាល់ខ្លះផ្សេងទៀត ឬក៏ទទួលបានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុផ្ទាល់ខ្លះផ្សេងទៀត។*

• *សមាជិកក្រុមប្រឹក្សាគាំទ្រការយល់ស្របលើគោលនយោបាយជាក់លាក់ណាមួយ ដែលរដ្ឋាភិបាល អង្គភាព ឬអង្គការរបស់ខ្លួននឹងទទួលបានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុផ្ទាល់ខ្លះ*

• *សមាជិកក្រុមប្រឹក្សាប្រើប្រាស់តំណែងរបស់ពួកគេនៅក្នុងក្រុមប្រឹក្សា គាំទ្រការយល់ស្រប ឬស្វែងរកការយល់ស្របលើកិច្ចសន្យាសេវាកម្មណាមួយរវាងមូលនិធិ និងស្ថាប័នជាសហការី ឬ*

• *សមាជិក TRP ដែលជានិយោជិករបស់រដ្ឋាភិបាល សាជីវកម្ម ឬអង្គការដែលចូលរួមក្នុងការវាយតម្លៃគម្រោងសុំជំនួយ ដែលស្ថាប័នជាសហការីទទួលផលប្រយោជន៍ធំដុំណាមួយ ។*

*ក្នុងគោលការណ៍ ទំនាស់មិនកើតឡើងនោះទេ នៅពេលដែលបុគ្គលលាក់បំបាំង ឬសហការី ឬស្ថាប័នជាសហការី ប្រឈមមុខទទួលផលប្រយោជន៍សាយចេញពីសកម្មភាពដែលគេកំពុងពិភាក្សា ។ ឧទាហរណ៍ សមាជិកក្រុមប្រឹក្សាម្នាក់មិនមានទំនាស់ផលប្រយោជន៍ពីសេចក្តីពិចារណារបស់គាត់លើសំណើសុំជំនួយនោះទេ ប្រសិនបើប្រទេសរបស់គាត់បានទទួលផលប្រយោជន៍សុខភាពប្រជាជនទូទៅ ឬនៅពេលណាដែលអង្គភាពឬអង្គការមិនមែនរដ្ឋាភិបាលធ្វើសាជីវកម្មក្នុងប្រទេសរបស់គាត់ទទួលបានផលប្រយោជន៍សាយចេញជាលទ្ធផលនៃការផ្តល់ជំនួយ ប៉ុន្តែនៅក្នុងករណីដែលរដ្ឋាភិបាល ឬអង្គភាពរបស់រដ្ឋាភិបាលនោះ មិនចូលរួមដោយផ្ទាល់នៅក្នុងការអនុវត្តន៍របស់ខ្លួន ។*

បញ្ជីទាំងនេះគ្រាន់តែជាឧទាហរណ៍ មិនមែនមានចេតនារៀបរាប់ហេតុការណ៍ទាំងអស់ដែលកើតមានទំនាស់ផលប្រយោជន៍បច្ចុប្បន្ន និងឬទំនាស់ដែលអាចកើតឡើងនោះទេ គឺគ្រាន់តែបញ្ជាក់គោល-ការណ៍ដែលមូលនិធិនឹងត្រូវគោរពតាម ពេលលើកនិយាយពីទំនាស់ទាំងនេះ នៅពេលកើតឡើង ។ ស្ថានភាពនីមួយៗនឹងត្រូវគេវាយតម្លៃ ទៅតាមការពិត និងកាលៈទេសៈជាក់លាក់នៃស្ថានភាពនោះ ប៉ុន្តែការសម្រេចចិត្តនឹងត្រូវធ្វើតាមគន្លងគោលការណ៍ណែនាំដែលបានចែងនៅក្នុងគោលនយោបាយនេះ ដែលត្រូវអនុវត្តទៅលើសកម្មភាពទាំងអស់ដែលទទួលការឧបត្ថម្ភ ឬគាំទ្រដោយមូលនិធិជាសាធារណៈ និងឯកជន ក៏ដូចជារកប្រាក់ចំណេញ និងមិនរកប្រាក់ចំណេញ ។

**4. តម្លាភាពនិងការលាតត្រដាង**

4.1 បុគ្គលលាក់បំបាំងទាំងអស់មានកាតព្វកិច្ចលាតត្រដាងនូវរាល់ទំនាស់ផលប្រយោជន៍បច្ចុប្បន្ន ឬទំនាស់ដែលអាចកើតឡើង រួមទាំងទំនាស់កើតមកពីសហការី ឬស្ថាប័នជាសហការី និងលក្ខណៈនៃទំនាស់ទាំងនោះ នៅពេលណាដែលបុគ្គលលាក់បំបាំងនោះបានដឹងថាទំនាស់មួយបានកើតឡើង ឬថាទំនាស់មួយប្រហែលជាអាចកើតឡើង ឬថាមានសញ្ញានៃការលេចចេញទំនាស់ឡើង ។

4.2 បុគ្គលលាក់បំបាំងទាំងអស់ ត្រូវបំពេញនិងប្រគល់ "សេចក្តីរាយការណ៍ស្តីពីផលប្រយោជន៍" ដែលភ្ជាប់មកជាមួយ ឱ្យមន្ត្រីត្រួតពិនិត្យសីលធម៌ ។ [3]

4.3 សេចក្តីថ្លែងការណ៍លាតត្រដាង ត្រូវធ្វើឱ្យមានព័ត៌មានថ្មីៗជារៀងរាល់ឆ្នាំ និងនៅពេលណាដែលមានការកែប្រែសំភារៈនៅក្នុងព័ត៌មានដែលសេចក្តីថ្លែងការណ៍ទាំងនោះផ្ទុក និងត្រូវថែទាំដោយមន្ត្រីត្រួតពិនិត្យសីលធម៌ និងត្រូវអាចឱ្យគណៈកម្មាធិការត្រួតពិនិត្យសីលធម៌ត្រួតពិនិត្យបាន និងចាត់ទុក

ថាត្រឹមត្រូវដោយគណៈកម្មាធិការត្រួតពិនិត្យសីលធម៌ ដោយក្រុមប្រឹក្សាតែប៉ុណ្ណោះ ។ ក្រៅពីបានរៀបរាប់ខាងលើ សេចក្តីថ្លែងការណ៍ទាំងនេះត្រូវទុកជាការសម្ងាត់ ។

4.4 និយោជិតត្រូវស្នើសុំការអនុញ្ញាតពីប្រធានប្រតិបត្តិ មុនពេលយល់ព្រមទទួលការិយាល័យ ឬអាជីពមួយ ក្រៅពីកាតព្វកិច្ចមុខងាររបស់ខ្លួននៅក្នុងមូលនិធិ ឬយល់ព្រមទទួលកិត្តិយស និងការតុបតែងពីភាគីខាងក្រៅ ប្រសិនបើសកម្មភាពដែលបានស្នើឡើងអាចនឹងធ្វើឱ្យកើតមានទំនាស់ផលប្រយោជន៍បច្ចុប្បន្ន និងទំនាស់ដែលអាចកើតឡើង ឬសញ្ញានៃការការលេចចេញទំនាស់នេះឡើង ។ សំណើបែបនេះ ត្រូវធ្វើតាមនីតិវិធីដែលបានចែងនៅក្នុងផ្នែក 5.4 នៃគោលនយោបាយនេះ ។

**5. នីតិវិធីពេលមានទំនាស់ផលប្រយោជន៍**

5.1 ទំនាស់ផលប្រយោជន៍បច្ចុប្បន្ន និងទំនាស់ដែលអាចកើតឡើង ឬសញ្ញានៃការលេចចេញទំនាស់ត្រូវលាតត្រដាងជាបន្ទាប់ ជាលាយលក្ខណ៍អក្សរទៅកាន់គណៈកម្មាធិការត្រួតពិនិត្យសីលធម៌របស់មូលនិធិ តាមរយៈមន្ត្រីត្រួតពិនិត្យសីលធម៌ ។ បុគ្គលទាំងឡាយត្រូវបានជម្រុញឱ្យធ្វើការពិភាក្សាជាមួយនឹងមន្ត្រីត្រួតពិនិត្យសីលធម៌ ឬសមាជិកគណៈកម្មាធិការត្រួតពិនិត្យសីលធម៌ដើម្បីទទួលយកគោលការណ៍ណែនាំ ប្រសិនបើមានសំនួរចំពោះការអនុវត្តន៍គោលនយោបាយនេះ ។

5.2 វាគឺជាកាតព្វកិច្ចរបស់គណៈកម្មាធិការត្រួតពិនិត្យសីលធម៌ ក្រោមជំនួយពីមន្ត្រីត្រួតពិនិត្យសីលធម៌ក្នុងការត្រួតពិនិត្យសារឡើងវិញនូវសេចក្តីលាតត្រដាងទាំងនេះ និងសម្រេចចិត្តថាតើទំនាស់ផល-ប្រយោជន៍បច្ចុប្បន្ន ឬទំនាស់ដែលអាចកើតឡើង បានកើតឡើងដែរឬទេ ហើយប្រសិនបើមាន ថាតើគួរចេញសំបុត្រលើកលែងស្តីពីកម្រិតណាដែលបុគ្គលលាក់បំបាំងអាចចូលរួមក្នុងកិច្ចពិភាក្សាលើបញ្ហាដែលនាំឱ្យមានទំនាស់នេះ ។ គណៈកម្មាធិការត្រួតពិនិត្យសីលធម៌អាចនឹងប្រាប់ក្រុមប្រឹក្សាទាំងមូលនូវបញ្ហាទំនាស់ណាមួយ ដោយការប្រុងប្រយ័ត្ន (មិនរាប់បញ្ចូលបុគ្គលម្នាក់ ឬបុគ្គលច្រើននាក់ដែលមានទំនាស់អាចកើតឡើង) យកមកពិភាក្សា និងធ្វើការសម្រេចចិត្ត ។

5.3 នៅពេលដែលទំនាស់ផលប្រយោជន៍បច្ចុប្បន្ន និងទំនាស់ដែលអាចកើតឡើង ត្រូវបានគេកំណត់ថាកើតមាន បុគ្គលលាក់បំបាំងមិនត្រូវចូលរួមក្នុងបញ្ហាដែលនាំឱ្យមានទំនាស់ ដោយគ្មានសេចក្តីលើកលែងពីគណៈកម្មាធិការត្រួតពិនិត្យសីលធម៌នោះទេ ។ ទាក់ទងនឹងក្រុមប្រឹក្សានេះ មានន័យថាបុគ្គលលាក់បំបាំងមិនត្រូវបោះឆ្នោត ឬបញ្ចេញមតិលើបញ្ហានេះ និងត្រូវអវត្តមានដោយគ្មានយោបល់មុនកិច្ចពិភាក្សា ឬការបោះឆ្នោតលើបញ្ហានេះចាប់ផ្តើម លុះត្រាតែសេចក្តីលើកលែងត្រូវបានផ្តល់ឱ្យដោយគណៈកម្មាធិការត្រួតពិនិត្យសីលធម៌ ។ សេចក្តីលើកលែងអាចនឹងត្រូវធ្វើឡើង ដើម្បីអនុញ្ញាតឱ្យមានការចូលរួមក្នុងកម្រិតណាក៏ដោយដែលគណៈកម្មាធិការត្រួតពិនិត្យសីលធម៌ យល់ថាត្រឹមត្រូវ ។ ឧទាហរណ៍ដូចជា សេចក្តីលើកលែងនេះអាចនឹងអនុញ្ញាតឱ្យបុគ្គលលាក់បំបាំងលើកបង្ហាញព័ត៌មានលក្ខណៈបច្ចេកទេស ប៉ុន្តែមិនមែនផ្តល់អនុសាសន៍នោះទេ ។ ឬក៏វាអាចអនុញ្ញាតឱ្យបុគ្គលលាក់

បំបាំងចូលរួមក្នុងកិច្ចប្រជុំ ដើម្បីបំពេញ ទំនួលខុសត្រូវរដ្ឋបាលរបស់បុគ្គលនោះ ប៉ុន្តែមិនមែនចូលរួមក្នុងកិច្ចប្រជុំស្តីពីបញ្ហាណាដែលនាំឱ្យមានទំនាស់ផលប្រយោជន៍នោះទេ ។ ឈ្មោះរបស់បុគ្គលលាក់បំបាំងដែលមានទំនាស់ផលប្រយោជន៍បច្ចុប្បន្ន ឬទំនាស់ដែលអាចកើតឡើង ដែលចូលរួមក្នុងកិច្ចប្រជុំណាមួយ និងបញ្ហាដែលនាំឱ្យមានទំនាស់ ត្រូវកត់បញ្ចូលក្នុងកំណត់ហេតុកិច្ចប្រជុំនោះ ។

5.4 នៅក្នុងការពិគ្រោះសុំយោបល់ជាមួយនឹងគណៈកម្មាធិការត្រួតពិនិត្យសីលធម៌ ប្រធានប្រតិបត្តិអាចអនុញ្ញាតឱ្យនិយោជិតមូលនិធិសកលទទួល ឬកាន់ការិយាល័យ ឬអាជីព ក្រៅពីតួនាទីការងាររបស់ខ្លួនក្នុងមូលនិធិសកល ឬទទួលកិត្តិយស ឬការតុបតែងដែលភាគីខាងក្រៅផ្តល់ឱ្យ ។ នៅពេលដែលត្រូវស្នើសុំ គណៈកម្មាធិការត្រួតពិនិត្យសីលធម៌ត្រូវសរសេរថាតើការអនុញ្ញាតនេះ នឹងនាំឱ្យមានលទ្ធផលជាទំនាស់ផលប្រយោជន៍បច្ចុប្បន្ន ឬទំនាស់ដែលអាចកើតឡើងដែរឬទេ ។

5.5 នៅពេលដែលក្រុមប្រឹក្សាពិចារណាលើក្រុមសំណើរសម្រាប់ការផ្តល់ការយល់ស្រប ជាទូទៅការចូលរួមរបស់សមាជិកក្រុមប្រឹក្សានៅក្នុងការពិចារណាមិនត្រូវចាត់ទុកថាជាទំនាស់ផលប្រយោជន៍នោះទេ បើទោះបីជាប្រទេស ឬអង្គភាពដែលសមាជិកនោះតំណាង អាចទទួលផលប្រយោជន៍ផ្ទាល់នៅក្នុងសំណើនៅក្នុងក្រុមនោះ ។ នៅពេលដែលក្រុមប្រឹក្សាពិចារណាលើសំណើជាក់លាក់ បុគ្គលលាក់បំបាំង ឬជនណាផ្សេងទៀត ត្រូវជម្រាបក្រុមប្រឹក្សាអំពីទំនាស់ផលប្រយោជន៍បច្ចុប្បន្ន ឬទំនាស់ដែលអាចកើតឡើង និងធ្វើតាមនីតិវិធីដែលបានចែងនៅក្នុងគោលនយោបាយនេះ ។

5.6 ប្រសិនបើបុគ្គលលាក់បំបាំងត្រូវបានរកឃើញថាមានទំនាស់ផលប្រយោជន៍បច្ចុប្បន្ន ឬទំនាស់ដែលអាចកើតឡើង ដែលមិនបានលាតត្រដាងដូចដែលតម្រូវខាងលើ ឬគណៈកម្មាធិការត្រួតពិនិត្យសីលធម៌មានហេតុផលសមរម្យជឿថា បុគ្គលលាក់បំបាំងមិនបានលាតត្រដាងពីទំនាស់ផលប្រយោ-ជន៍បច្ចុប្បន្ន ឬទំនាស់ដែលអាចកើតឡើង គណៈកម្មាធិការនឹងប្រាប់បុគ្គលលាក់បំបាំងអំពីមូលដ្ឋានជំនឿនេះ និងផ្តល់ឱកាសឱ្យគេពន្យល់នូវការខកខានមិនបានលាតត្រដាងដូចដែលបានពោល ។ ប្រសិនបើគណៈកម្មាធិការត្រួតពិនិត្យសីលធម៌នឹងសម្រេចថាជាការពិត អ្នកទទួលផលប្រយោជន៍មិនបាន លាតត្រដាងពីទំនាស់ផលប្រយោជន៍បច្ចុប្បន្ន ឬទំនាស់ដែលអាចកើតឡើងពិតប្រាកដ ឬចាំបាច់បន្ទាប់ពីស្តាប់ចំលើយ និងធ្វើការស៊ើបអង្កេតបន្តទៅទៀតដូចដែលបានធានា គណៈកម្មាធិការត្រូវផ្តល់ដំណឹងដល់ក្រុមប្រឹក្សា ។

## 6. អំណោយ

6.1 បុគ្គលលាក់បំបាំង និងសហការីត្រូវបានហាមឃាត់ក្នុងការទទួលអំណោយនានាក្នុងកាលៈទេសៈណាដែលគេគិតថា អំណោយនោះត្រូវបានយកមកឡើងតំណែងបុគ្គលលាក់បំបាំង និងផ្តល់ប្រយោជន៍ដែលមូលនិធិអាចបង្កការប៉ះពាល់ជាខ្លាំង ។ បុគ្គលលាក់បំបាំង និងសហការីទាំងអស់ត្រូវបានហាមឃាត់ក្នុងការផ្តល់អំណោយ នៅពេលណាដែលគេគិតថា អំណោយនោះមានចេតនា

ប៉ះពាល់គោលនយោបាយ ឬសកម្មភាពនានារបស់មូលនិធិ ឬកម្មវិធីណាមួយដែលមូលនិធិផ្តល់ជំនួយ ។ គណៈកម្មាធិការត្រួតពិនិត្យសីលធម៌អាចលើកលែងលក្ខខ័ណ្ឌនេះតាមការគួរ ។

6.2 ករណីលើកលែង

(a) បុគ្គលលាក់បំបាំងអាចទទួលអំណោយដែលមិនបានស្នើសុំតំណាងឱ្យមូលនិធិ នៅពេលដែលការបដិសេធមិនទទួល មិនស្ថិតក្នុងចំណាប់អារម្មណ៍របស់មូលនិធិ ។ អំណោយដែលត្រូវបានទទួលតំណាងឱ្យមូលនិធិ នឹងត្រូវផ្ញើរទៅកាន់លេខាធិការដ្ឋាន និងដោះស្រាយតាមនីតិវិធីដែលរៀបចំឡើងដោយលេខាធិការដ្ឋាន ។

(b) បុគ្គលលាក់បំបាំងអាចទទួលអំណោយដែលមិនបានស្នើសុំ ឬផ្តល់អំណោយដែលមានតម្លៃសរុប $20 ឬតិចជាង ប្រសិនបើតម្លៃសរុបនៃអំណោយនីមួយៗដែលបានទទួល ឬផ្តល់ឱ្យនរណាម្នាក់មិនលើសពី $50 ក្នុងរយៈពេលមួយឆ្នាំប្រតិទិន ។

(c) ពិធីជួបជុំ ឬព្រឹត្តការណ៍ផ្សេងៗដែលមានការចូលរួមយ៉ាងទូលំទូលាយ ។

(i) នៅពេលដែលបុគ្គលលាក់បំបាំងត្រូវបានគេស្នើឱ្យលើកបង្ហាញព័ត៌មាន តំណាងឱ្យមូលនិធិនៅក្នុងសន្និសីទ ឬព្រឹត្តការណ៍ផ្សេងៗ ការមិនយកថ្លៃចូលរួមក្នុងព្រឹត្តការណ៍នោះ មិនស្ថិតក្នុងគោលនយោ-បាយនេះទេ បើសិនបើបានផ្តល់ឱ្យដោយម្ចាស់ឧបត្ថម្ភព្រឹត្តការណ៍ ។

(ii) ពិធីជួបជុំដែលមានការចូលរួមយ៉ាងទូលំទូលាយ ។ លេខាធិការដ្ឋានអាចយល់ព្រមលើការចូលរួមមិនគិតថ្លៃ សម្រាប់បុគ្គលនីមួយៗនៅក្នុងពិធីជួបជុំដែលមានការចូលរួមយ៉ាងទូលំទូលាយ ទៅតាមលក្ខណៈករណីមួយទៅករណីមួយ និងអាចរៀបចំនីតិវិធីនៃការចូលរួមបែបនេះ ជំនួសឱ្យការយល់ព្រមរបស់បុគ្គលម្នាក់ៗ ។ ក្នុងការកំណត់ថាការយល់ស្របនេះត្រឹមត្រូវដែរឬទេ លេខាធិការដ្ឋានគួរចាត់ទុកថាពិធីជួបជុំដែលមានការចូលរួមយ៉ាងទូលំទូលាយ ជាពិធីដែលគេគិតថាមានចំនួនមនុស្សច្រើននឹងចូលរួម និងដែលគេគិតថាអ្នកមានចំណាប់អារម្មណ៍ និងគំនិតចម្រុះនឹងមានវត្តមាន ពីព្រោះថាកម្រិតនៃឥទ្ធិពលបច្ចុប្បន្នជាក់ស្តែងលើបុគ្គលលាក់បំបាំងត្រូវបានកាត់បន្ថយគ្រប់គ្រាន់ ។

## 7. ការងារពីរដ្ឋលេខាធិការដ្ឋានមូលនិធិសកល

ជនទាំងឡាយណាដែលបម្រើការងារជាសមាជិកក្រុមប្រឹក្សា អ្នកជំនួស សមាជិកគណៈកម្មាធិការក្រុមប្រឹក្សា ឬជាប្រធាន ឬអនុប្រធានក្រុមត្រួតពិនិត្យបច្ចេកទេសសារឡើងវិញ មិនមានសិទ្ធទទួលយកការងារពីលេខាធិការដ្ឋានមូលនិធិសកលនោះទេ រហូតទាល់តែបានមួយឆ្នាំបន្ទាប់ពីថ្ងៃចុងក្រោយនៃការបម្រើការងារក្នុងមុខតំណែងនោះ ។ គណៈកម្មាធិការត្រួតពិនិត្យសីលធម៌ អាចលើកលែងលក្ខ-ខ័ណ្ឌនេះតាមការគួរ ។ សំណើសុំសេចក្តីលើកលែងនេះ ត្រូវប្រគល់ឱ្យដោយជនណាដែលពាក់ព័ន្ធទៅកាន់គណៈកម្មាធិការត្រួតពិនិត្យសីលធម៌ មុនពេលដែលជននោះសុំការងារពីលេខាធិការដ្ឋាន ។

លេខាធិការដ្ឋានមិនត្រូវចាត់វិធានការ ឬទទួលពាក្យសុំការងារពីជននេះនោះទេ លុះត្រាតែគណៈ-កម្មាធិការត្រួតពិនិត្យសីលធម៌ចេញសេចក្តីលើកលែងសិន ។

**8. ការចូលរួមដោយគ្មានសំណងពីសហការី**

សហការីនៃនិយោជិតលេខាធិការដ្ឋាន មិនត្រូវពាក់ព័ន្ធនឹងការងារដោយគ្មានសំណងទាំងក្នុង និងក្រៅមូលនិធិសកល ។

**9. យន្តការសម្របសម្រួលប្រចាំប្រទេស**

ប្រតិបត្តិការដែលមានតម្លាភាពរបស់យន្តការសម្របសម្រួលប្រចាំប្រទេស គឺជាការចាំបាច់ក្នុងការអនុវត្តន៍កម្មវិធីជាក់ស្តែងដែលផ្តល់ជំនួយដោយមូលនិធិសកល និងក្នុងភាពសុចរិតនៃការរីកលូតលាស់ សំណើ និងយល់ព្រម ។ តាមការគួរ បុគ្គលលាក់បំបាំងជាការត្រឹមត្រូវ ត្រូវប្រើប្រាស់កិច្ចខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពរបស់ខ្លួនដោយខ្លួនឯង ឬតាមរយៈស្ថាប័នជាសហការី ក្នុងការធានាថា យន្តការសម្របសម្រួលប្រចាំប្រទេស ដំណើរការក្នុងតម្លាភាព និងការពារប្រឆាំងនឹងទំនាស់ផលប្រយោជន៍យ៉ាងសកម្ម ។

**10. ការផ្សព្វផ្សាយនិងត្រួតពិនិត្យគោលនយោបាយសារឡើងវិញ**

10.1 លេខាធិការដ្ឋានមូលនិធិត្រូវចែកចាយសំណៅចម្លងគោលនយោបាយនេះ ឱ្យបុគ្គលលាក់បំបាំងជារៀងរាល់ឆ្នាំ ក៏ដូចជាសំណៅចម្លងបែបបទនៃសេចក្តីរាយការណ៍ពីផលប្រយោជន៍ ។

10.2 សំណៅចម្លងគោលនយោបាយនេះ និងបែបបទនៃសេចក្តីរាយការណ៍ពីផលប្រយោជន៍ ត្រូវផ្សព្វផ្សាយនៅលើវេបសាយមូលនិធិ ។

[1] និយោជិតមានវិជ្ជាជីវៈ គឺជាជនណាដែលមានអំណាចសំខាន់ក្នុងការសម្រេចចិត្ត ផ្ទុយពីមុខងារបុគ្គលិកជំនួយ ។ ប្រធានប្រតិបត្តិការ នឹងកំណត់ថាតើជនណាម្នាក់ត្រូវបានរាប់បញ្ចូលក្នុងកាលៈទេសៈណាដែលមិនមានភាពច្បាស់លាស់ ។

[2] ទាក់ទងនឹងសមាជិកក្រុមប្រឹក្សា និងបុគ្គលលាក់បំបាំងទាំងនោះដែលបម្រើការងារក្នុងមូលនិធិជាតំណាងអង្គភាព ឬរដ្ឋាភិបាល ប្រទេសជាតិ គ្មានព័ត៌មានណាមួយក្នុងឯកសារនេះនឹងត្រូវបកស្រាយ ជាការហាមឃាត់មិនឱ្យមានការចូលរួមពីបុគ្គលនោះក្នុងបញ្ហាដែលស្ថិតក្រោមការពិចារណា ដែលនឹងប៉ះពាល់ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុរបស់អង្គភាព ឬរដ្ឋាភិបាលនៃប្រទេសជាតិនោះដោយផ្ទាល់ ឬដោយប្រយោល លើកលែងតែសមាជិកក្រុមប្រឹក្សា ឬបុគ្គលលាក់បំបាំងផ្សេងទៀតត្រូវចូលរួមក្នុងការពិចារណាអំពីសំណើរសុំជំនួយជាក់លាក់ណាមួយដែលត្រូវបានប្រគល់ឱ្យដោយអង្គភាព ឬរដ្ឋាភិបាលនោះ ឬការសម្រេចចិត្តណាមួយដែលអង្គភាព ឬរដ្ឋាភិបាលអាចទទួលផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុផ្ទាល់ពីការសម្រេចចិត្តនោះ (ដូចជាជំនួយ កិច្ចសន្យា ឬគោលនយោបាយ) បើសិនជាការចូលរួមនោះគ្មានការអនុញ្ញាតពីក្រុមប្រឹក្សា ។

[3] ក្នុងក្រម ឬបទបញ្ជាប្រភេទនេះ បុគ្គលលាក់បំបាំងដែលត្រូវគោរពតាមក្រមសីលធម៌ ឬបទដ្ឋានបទបញ្ជាសីលធម៌រួចហើយនោះ និងជាអ្នកដែលគេតម្រូវឱ្យបំពេញ និងសរសេរបែបបទលាតត្រដាងដែលរួមមានព័ត៌មានស្មើក្នុងសេចក្តីរាយការណ៍ពី

ផលប្រយោជន៍ដែលភ្ជាប់មកជាមួយ អាចប្រគល់បែបបទនេះជំនួសសេចក្តីរាយការណ៍ពីផលប្រយោជន៍ដែលភ្ជាប់មកជាមួយ ។

[4] ចំពោះបុគ្គលលាក់បំបាំងដែលបម្រើការងារនៅក្នុងមូលនិធិជាតំណាងរដ្ឋាភិបាល សាជីវកម្ម ឬអង្គការ និងនៅពេលណាដែលបុគ្គលនេះត្រូវគោរពតាមក្រមសីលធម៌ និងបទដ្ឋានបទបញ្ជាសីលធម៌ ជាលទ្ធផលនៃមុខតំណែងនោះ បុគ្គលនោះអាចទទួលការអញ្ជើញចូលរួមដោយសេចក្តីរាប់អានក្នុងពិធីជួបជុំដែលមានការចូលរួមយ៉ាងទូលំទូលាយ បើសិនជាគោលនយោ-បាយនេះមិនបានហាមឃាត់ នៅពេលដែលការចូលរួមត្រូវបានអនុញ្ញាតក្រោមក្រមសីលធម៌ ឬបទដ្ឋានសីលធម៌ដែល គួល នេះត្រូវធ្វើ ។